# ព្រះខែថ្មីក្នុងរាត្រីចាស់

ស្នាដៃរឿងខ្លីទី៤

និពន្ធដោយ ម៉ា ច័ន្ទបញ្ញា

មានសំណួរមួយចេះតែចោទសួរល្វើយៗក្នុងចិត្តខ្ញុំថា តើខ្ញុំជានរណា? តើខ្ញុំចង់បានអ្វី? បើផ្លូវដែលខ្ញុំចង់ដើរពេលនេះបាននឹងកំពុងធ្វើវាហើយ។ ពេលវេលាពិតជាយូរណាស់សម្រាប់ មនុស្សដែលរង់ចាំក្ដីប្រាថ្នារបស់ខ្លួន និងចង់ដឹងថាខ្លួនជានរណា។ បានស្គាល់ខ្លួនឯងហើយ ក៏មិនដឹងថាខ្លួនឯងចង់បានអ្វីទៅវិញ?

សំឡេងស៊ីភ្លេរបស់រថយន្តហោះកាត់ត្រចៀករបស់ខ្ញុំ ធ្វើឲ្យខ្ញុំភ្ញាក់ខ្លួនព្រឺតពីយល់សប្តិក្នុងព្រឹកព្រលឹមដ៏ខ្លី ដែលកំពុងបញ្ចេញរស្មីព្រាងៗលើផ្សារធំថ្មីទើបនឹងជួសជុលរួច។ ខ្ញុំមិនមែនជាមនុស្សតែម្នាក់ទេ ដែលធ្វើដំណើរលើដងវិថីដ៏មមាញឹកនេះ តែខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាច្រើននាក់ដែលមានទិសដៅផ្សេងៗគ្នា នៅលើវិថីតែមួយនេះ។ តើមនុស្សទាំងនោះក៏គិតដូចខ្ញុំដែរទេហ្ន៎? តើគេស្គាល់ខ្លួនគេ ថាជានរណាគេឬទេ? តើគេដឹងថាខ្លួនគេចង់បានអ្វីឬទេហ្ន៎?

ប៉ុន្តែនិយាយតាមត្រង់ទៅចុះ ខ្ញុំមិនចូលចិត្តអ្នកណាអាងខ្លួនឯងមានអំណាច ហើយធ្វើអីស្រេចតែចិត្តនោះទេ។ គំនិតនេះ ស្តាប់ទៅហាក់ដូចជាទុតិដ្ឋិនិយមបន្តិចមែន តែឧត្តមគតិបង្គាប់ច្បាស់ហើយ គឺមិនចង់ក្បត់ខ្លួនឯង។ ខ្ញុំក៏ក្រឡេកឃើញបុរសក្នុងឡាន ដែលកំពុងខំអើតមើលតាមទម្លាប់ខិលខូចរបស់បុរសទូទៅដែលមិនឲ្យតម្លៃស្ត្រីភេទវិញ។ បុរសបែបនេះ មុខក្រាស់ណាស់ មើលប៉ុណ្ណេះហើយ នៅតែមិនជៀសទៀត មិនរវល់ទេ ខ្ញុំក៏ជិះចេញទៅបែកពីទិសដៅបុរសនោះទៅ។

គំនិតចេះតែមាន ឯការធ្វើដំណើរនៅតែបន្ត មិនយូរប៉ុន្មានផងខ្ញុំក៏ធ្វើដំណើរដល់ក្រុមហ៊ុនដែលខ្ញុំធ្វើការ។ ក្រុមហ៊ុននេះ គឺជាក្រុមហ៊ុនមួយដែលខ្ញុំចូលធ្វើការដំបូងបង្អស់ក្នុងជីវិតបន្ទាប់ពីបានបញ្ចប់មហាវិទ្យាល័យនៃកាតព្វកិច្ចជីវិតរួចមក។ ខ្ញុំជាស្ត្រីមែន តែការងារដែលខ្ញុំធ្វើនេះ បែរជាខុសពីស្ត្រីដទៃទៅវិញ អាចថាចម្លែកបានតែមិនប្លែកទេសម្រាប់មនុស្សសព្វថ្ងៃនេះ។

«ម៉ាលីន! ហើយម៉េច បានថ្ងៃនេះម៉ាលីនឯងមកធ្វើការលឿនម្ល៉េះ? គេងមិនលក់ពីយប់ហ៎? មុខឯងដូចជាស្លេកស្លាំងខ្លាំងណាស់នៀក? ប្រយ័ត្នឈឺណា៎ក្មួយ»

មីងអម គឺជាបុគ្គលិកផ្នែកអនាម័យ។ គាត់មានសម្បុរស្រអែម មុខមានស្នាមជាំ កម្ពស់គាត់មិនសូវជាខ្ពស់ ហើយក៏មិនសូវទាបដែរ ដូចជាខ្ញុំដែរ។

«ចាំ! មីង! យប់មិញ គេងមិនលក់សោះ បានជាឥឡូវមុខស្លេកស្លាំងអស់ហើយ មីងថ្ងៃនេះអត់យកលុយទៅផ្ញើកូនដូចរាល់ខែទេឬ?»

មីងអម ញញឹមទាំងមានញើសសស្រាក់ ជាមួយសម្លៀកបំពាក់ជាឯកសណ្ឋានបុគ្គលិកអនាម័យ ឯដៃកាន់អំបោសជូតទឹក អូសបណ្ដើរ ងើយនិយាយមើលមុខខ្ញុំបណ្ដើរ។

«នែ! ខែនេះមីងចង់សន្សំវាខ្លះ ព្រោះឥឡូវនេះកូនៗរបស់មីងគេមានការងារធ្វើគ្រប់គ្នា អស់ហើយ នឹកថាពីរបីឆ្នាំទៀត មីងនឹងយកលុយទាំងនោះ ទុកគ្រាន់រៀបចំទុកដាក់គ្រួសារឲ្យវា។»

ព្រោះតែជីវភាពគ្រួសារ កូនៗ និងណាមួយខ្លួនគាត់ត្រូវរងបន្ទុកជាមេម៉ាយ ដែលប្ដីបានស្លាប់កាលពីជំនាន់ប៉ុល ពតនោះ គាត់ក៏សម្រេចចិត្តមកធ្វើការជាអ្នកអនាម័យនៅភ្នំពេញនេះ។ គាត់តែងតែសួរសុខទុក្ខខ្ញុំបែបនេះ ស្ទើររាល់ព្រឹកទៅហើយ។

ក្នុងឯកសណ្ឋានឈុតខ្មៅ សំពត់ខ្លីត្រឹមជង្គង់ចុះក្រោមបន្តិច និងមានក្រណាត់សថែមមួយស្រទាប់ទៀត។ ស្មារខាងស្ដាំរបស់ខ្ញុំជាប់ជាមួយនឹងកាបូបយួរដៃធំល្មម ភ្នែករបស់ខ្ញុំពុំបានរំពៃមើលមុខគាត់ត្រឡប់វិញនោះទេ ព្រោះអាល័យតែមើលមុខដែលស្លេកស្លាំងបន្តិច តែអាចស្ដាប់ដឹងពីសម្ដីនោះ។ ស្ដាប់ទៅ គាត់គឺជាមនុស្សគិតគូរសុខទុក្ខដល់កូនចៅសម្បើមណាស់ គួរឲ្យគោរពគាត់មែន។

«អូ! ស្ដាប់ទៅអត់សសើរមីងមិនបានសោះ។ ស្គាល់មីងយូរហើយ មិនដឹងដែរថាមីងជាអ្នកស្រុកណាសោះ! មីងជាអ្នកនៅស្រុកណាដែរ? ស្ដាប់ពាក្យមីងទៅដូចជាអ្នកភ្នំពេញម៉េចទេ?»

«អូ! អូ! អត់ទេ! មីងនែ! មីង! ជាអ្នកស្រុក កំពង់ចាមណាក្មួយ»

«អូ! ដូចស្រុកកំណើតម៉ាក់ខ្ញុំដែរ តែស្ដាយណាស់គាត់បានស្លាប់បាត់ទៅហើយ។ ខ្ញុំមិនដែលឃើញមុខគាត់ផង ឮតែប៉ានិយាយប្រាប់។ អូ! មីង! ខ្ញុំដល់ម៉ោងចូលការិយាល័យផង។ អូ! ស្អែកនេះសូមពឹងមីងជួយរៀបចំបន្ទប់ឲ្យបន្តិចផងណាំ! អរគុណមីង!»

«អើ! មីងដឹងហើយ ចូលធ្វើការចុះណាំ!»

ខ្ញុំលប់មុខហើយ ខ្ញុំក៏លាគាត់ចូលទៅការិយាល័យរបស់ខ្ញុំ ដែលនៅក្បែរបន្ទប់ជិតនេះ តែប្រមាណ១០ ទៅ ១៥ម៉ែត្រប៉ុណ្ណោះ។

ទ្វារបើកឡើង និមិត្តឡើងនូវសភាពពន្លឺស្រាលៗនៃព្រះអាទិត្យដែលកំពុងបង្អួតរាងបាញ់ព្រាតមកក្នុងផ្ទៃបន្ទប់របស់ខ្ញុំ។ ខ្ញុំធ្វើការតែម្នាក់ឯងទេ ក្នុងបន្ទប់នេះ ឯអ្នកដែលធ្វើការជាមួយខ្ញុំដទៃទៀត គឺគេធ្វើការមួយដំណាក់មុនខ្ញុំ។ ជិត៣ឆ្នាំមកហើយ ដែលខ្ញុំធ្វើការក្នុងការិយាល័យនេះ។ មិនសូវជាជាប់លាប់ទេ ព្រោះត្រូវចុះមើលការដ្ឋានជាមួយមិត្តរួមការងារញឹកញាប់។ ប្រាក់ខែ ខែក្រោយនេះ ខ្ញុំនឹងអាចបង្គ្រប់លុយទិញរថយន្តមួយប្រើនឹងគេហើយ។ ទិញបែបនេះ មិនមែនចង់អួតថាប្រាក់ខែខ្ញុំច្រើននោះទេ តែគឺទិញដោយសារតែលោកប៉ា ចេះតែព្រួយបារម្ភធ្វើការផ្លូវឆ្ងាយពេក ខ្លាចក្រែងមានគ្រោះថ្នាក់។ ហើយនិយាយទៅ តាមពិតព្រឹកនេះ មូលហេតុដែលខ្ញុំមកលឿននេះមិនមែនខ្ញុំគេងជ្រុលដំណេកអីទេ តាមពិតខ្ញុំរៀនក្រោកពីព្រលឹមឲ្យហើយ ដើម្បីឲ្យនៅពេលជិះរថយន្តនោះ ងាយស្រួលសម្រួលពេលវេលាដែលស្ទះផ្លូវអីផង។

គុក! គុក! សំឡេងគោះទ្វា បានបន្លឺឡើង រួចក៏បណ្តារឲ្យទ្វាច្រានចូលមកក្នុង ជាមួយនឹងនារីម្នាក់កាន់ឯកសារជាប់នឹងដៃ ក្នុងសម្លៀកបំពាក់ជាឯកសណ្ឋានក្រុមហ៊ុន និងអមព្រមជាមួយកែវស្នងភ្នែកដែលមានស៊ុមក្រាស់ខ្មីសពណ៌ខ្មៅ។

«យី! នីដា! ម៉ោះ! ម៉េចហើយ ការងារពីម្សិលនោះ?» នីដានិងខ្ញុំ គឺជាមិត្តរួមការងារនឹងខ្ញុំ។ គេជាលេខាបណ្តោះអាសន្នដែលខ្ញុំបានអញ្ជើញមក។ ខ្ញុំសួរទៅកាន់គេជាមុន រួចគេក៏តបវិញតាមទម្លាប់៖

«នែ! ថ្ងៃនេះឯងមកលឿនណាស់វី មុខនឹងដឹងថាមិនទាន់ញ៉ាំអីហើយទេ ចាំទៅញ៉ាំអីជុំគ្នា ម្តងឮនៅ?» ខ្ញុំឮសំណួរបែបនេះ ខ្ញុំក៏ចាប់ញញឹម រួចនីដាក៏បន្តទៀតថា៖«នែ! ការងារដែលដាក់ម្សិលមិញនេះ ឥឡូវគេយល់ព្រមធ្វើតាមយើងហើយ ក្បាច់សរសរទាំងអស់នឹងត្រូវផ្លាស់ប្តូរថ្មី តែគេថាគេចង់បានលក្ខណៈទាន់សម័យជាងនេះ តែឲ្យមានលក្ខណៈខ្មែរបានបាន!»

«ចុះណឹងគ្នាប្រាប់គាត់ហើយតើ គាត់មិនទាន់យល់ គ្នាថាក្រុមហ៊ុនយើងគឺនឹងធ្វើជាលក្ខណៈខ្មែរទំនើបជូនគាត់ តែគាត់ប្រកែក ឥឡូវណឹងដដែរ។» ខ្ញុំឆ្លើយតបនីដាវិញ។

«អ៊ីចឹង! ថ្ងៃណឹងប្រហែលម៉ោងបី ចាំចេញទៅមើលការដ្ឋានម្តងទៀតទៅណ៎ា ព្រោះគ្នាបានណាត់គេហើយ។»

«អូខេ! អ៊ីចឹងម៉ោងបី ចាំចេញទៅទាំងអស់គ្នាណ៎ា។» នីដា ញញឹមដាក់ខ្ញុំ ហើយរៀបឯកសារទុក

រួចនាងបន្តថា៖

«នែ! យ៉ាងម៉េចហើយ សាលាអង់គ្លេសរបស់ឯង? យប់មិញ ឮថាដាក់កិច្ចការឲ្យឯងចាស់ដៃតែម្តងហើយ។ លោកគ្រូណឹងណា អាងតែគាត់មិនមែនជាអ្នកធ្វើការ ឲ្យឯងទៅសរសេររឿងផ្ទាល់ខ្លួន ធ្វើមើលតែឯងនឹងជាអ្នកនិពន្ធល្បីមកពីណាអ៊ីចឹង។» នីដា ដឹងរឿងនេះ មកពីយប់មិញខ្ញុំបានហៅទៅសួរនាងអំពីរឿងខ្លះៗនឹងអាលរៀបចំគំនិតសរសេរ។

«ហ្អើយ! គ្នាក៏មិនយល់ដែរ។ សង្ឃឹមថាគាត់មិនមែនចង់ឲ្យគ្នាមានជំនាញជាអ្នកនិពន្ធមួយទៀតទៅចុះ។»

«ហាហ ហាហ! ត្រូវហើយ។ នែ! ថ្ងៃនេះ គ្នានាំឯងទៅញ៉ាំអី នៅកន្លែងបងប្រុសគ្នាម្តង។ គាត់ជាអ្នកតុបតែងហាងណឹងដោយផ្ទាល់ដៃណា៎! បើកយូរហើយ តែឃើញឯងរវល់ពេក ខ្ជិលហៅ ឥឡូវមើលមុខឯង ដូចជាធុញទ្រាន់ហើយ ចង់នាំឯងទៅប្តូរបរិយាកាសនៅណឹងម្តង»

បងប្រុសនីដា ជាអ្នកតុបតែងនិងរចនាទេ តែជារឿយៗ កាលពីនៅរៀនមហាវិទ្យាល័យ គាត់ចូលចិត្តថតរូបលេងណាស់ តែមែនទែនទៅគាត់ជាអ្នកឌីហ្សាញទេវិញ។ និស្ស័យមនុស្សគឺមើលមិនច្បាស់ទេ ដូចចិត្តមនុស្សដូច្នោះដែរ។

«អូខេ! អ៊ីចឹងក៏អ៊ីចឹងទៅ ព្រោះគ្នាខានជួបលោកបងណឹងយូរមកហើយ។»

«អ៊ីចឹងសម្រេចថាចឹងហើយ។ គ្នាចេញទៅហើយណា៎! ថ្ងៃជួបគ្នា»

«អូខេ!» ខ្ញុំញញឹមតប រួចក៏ទម្លាក់ទឹកមុខមកធម្មតាវិញ។

ថ្ងៃនេះ រាងអស់កម្លាំងណាស់ ព្រោះដូចជាក្រោកលឿនជាងរាល់ដងពេក ព្រឹកមិញនេះ។ កិច្ចការឥឡូវដូចជាច្រើនទៅៗហើយ ឯពេលសម្រាកក៏ខើចទៅៗ មិនមានពេលស្វែងយល់ពីខ្លួនឯងសោះ។ រឿងមួយដែលខ្ញុំចេះតែនឹកមិនយល់ ឆ្ងល់តាំងពីតូចមក ប៉ាប្រាប់ថាម៉ាក់ស្លាប់ តែហេតុអ្វីក៏គ្មានរូបថតសោះ? ហើយហេតុអី គាត់បែរជាឲ្យខ្ញុំទៅរស់នៅជាមួយលោកយាយទេវិញ។ អត់យល់! តើគាត់លាក់ខ្ញុំមានប្រយោជន៍អី? បានតែឲ្យខ្ញុំសួរខ្លួនឯងដដែរៗថាតើខ្លួនឯងជានរណាណឹង?

ហ្វេសប៊ុកឥឡូវស្ងាត់ម្ល៉េះ មិនដូចពីចេះលេងដំបូងទេ។ នេះប្រហែលជាមានន័យថា មនុស្សណា

ក៏ជាមនុស្សមិនទៀងដែរ។

«សួស្តីម៉ាលីន! សុខសប្បាយជាទេ?»

ឱ! លោកអើយ គ្រាន់តែនិយាយដើមក៏មានអ្នកសួរនាំភ្លាមហ្ន៎។

«ចាំ! ខ្ញុំសុខទេ ចុះអ្នកវិញ?»

«សុខតើ! ឥឡូវនេះ កំពុងធ្វើអីដែរណឹង? នៅកន្លែងធ្វើការឬ?»

«ចាំ! កន្លែងធ្វើការ។»

«អូ! ខ្ញុំចង់ប្រាប់ថា...»

សំឡេងទូរស័ព្ទIpone4របស់ខ្ញុំក៏ចាប់រោទិ៍ឡើង កាត់ចង្វាក់សន្ទនាតាមអក្សររបស់ខ្ញុំអស់រលីង។

«អាឡូ! ជម្រាបសួរ»

«អាឡូ! អាគារម៉ូលមិញនេះសល់តែរៀបចំខាងក្នុងទៀតទេហើយហើយ។ឯងមានស្គាល់ក្រុមហ៊ុនដេគ័រណាទេ ជួយទាក់ទងឲ្យផង។»

«អូ! ចាំ! ស្គាល់តើពូ! ថ្ងៃនេះ ខ្ញុំទៅជួបគាត់ណឹងហើយ ចាំមើលឲ្យគាត់ទាក់ទងទៅពូ!»

«អើ! អរគុណច្រើន! ចឹងបានហើយណាំ!»

«ចាំ! ចាំ! ចាំមើលថ្ងៃតិចណាពូ! ជម្រាបលា!»

«អើ! ដឹងហើយ!»

ជួបគ្នាមួយភ្លែត រួចក៏បែកគ្នាមួយភ្លែតដែរ ជីវិតគឺរស់បែបនេះហើយ បើមិនរស់ ជីវិតប្រហែលជាមិនមានន័យនោះទេ។ ដូចជាមានអារម្មណ៍ថាអស់កម្លាំងខ្លាំងមែនទែនហើយ ក្រែងធ្វើការបន្តមិនកើតខ្ញុំក៏ដើរទៅសម្រាកនៅលើសាឡុងពូកមួយ ដែលរៀបចំឡើងនៅក្បែរនោះសម្រាប់ភ្ញៀវមួយស្របក់ធំ។

ល្ងាចនេះ រងារប្លែកពីធម្មតា ថ្ងៃលិចពណ៌ក្រហមឆ្អិនឆ្អៅ កំពុងទេរទាបធ្លាក់ស្មើរនឹងស្នាមទ្រនៃដែនជើងមេឃ ទីដែលមនុស្សទូទៅយល់ថាជាទីមនោរម្យគ្មានទុក្ខព្រួយរបស់មនុស្សគ្រប់រូប។ សំឡេងរហៀកៗនៃខ្យល់បក់ កំពុងផាត់ប៉ះនឹងចុងស្រល់ររាំប្រៀបបាននឹងចិត្តមនុស្សលោកដែល គ្មានចិត្តស្មោះ

សូម្បីតែខ្លួនឯង។ ស្នូរជួងក្រឹមៗ បង្អូសសំឡេងឡើងពីវត្តមួយនៅក្បែរនោះ។ ក្រៅពីសំឡេងដែលស្និទ្ធនឹងធម្មជាតិមួយនេះ សំឡេងនៃមនុស្សចំណាស់ម្នាក់បានបន្លឺឡើងក្នុងបរិយាកាសដ៏មនោរម្យនេះថាៈ «ជីវិតមនុស្សគឺមិនទៀងទេ អ្វីដែលទៀងគឺភាពមិនទៀងទាត់នេះហើយ ចូរឯងដើរទៅតាមផ្លូវមួយដែលឯងយល់ថាត្រូវ និងមនុស្សដទៃយល់ថាត្រូវដែរចុះ ព្រោះសូម្បីតែឯងថយទៅក្រោយមួយជំហាន ក៏មានន័យថាឯងដើរទៅមុខមួយជំហៀនដែរ។ ពេលវេលាមានតម្លៃណាស់ ចូរឯងកុំខាតពេលដូចមនុស្សលោកសព្វថ្ងៃ។ ជើងមេឃថ្មីកំពុងចាំឯងហើយ! ទីនោះ ជាទីអវសាន្តនៃសំណួរផ្សេងៗ»។

មិនមែនតែសំឡេងទេដែរនិមិត្តឡើងក្នុងសោតារបស់ខ្ញុំ រូបរាងនារីចំណាស់ម្នាក់ ក៏ប្រតិដ្ឋឡើងជាស្រមោលក្នុងដួងនេត្រាដ៏ស្រពិចស្រពិលនេះដែរ។

«តើលោកយាយជានរណា? លោកយាយមកពីណា?...»

«មិនបាច់ឆ្ងល់ច្រើនទេ ការពិតនឹងប្រាប់ឯងក្នុងពេលដ៏ខ្លី... ម៉ាលីន... ម៉ាលីន... កូនមាសម្ដាយ! ម៉ាលីន...»

«ម៉ាលីន... ម៉ាលីន... ម៉ាលីន... ក្រោកឡើង នែ! យ៉ាងម៉េចហើយ»។

ងងឹតឈឹង តែហាក់ដូចជាដាននឹងព្រឹត្តិការណ៍ចាស់ត្រង់ណាម៉្យាង។ ភ្នែកខ្ញុំបើកឡើង ស្រាប់តែឃើញមុខនីដាយ៉ាងច្បាស់ក្រឡែត។ ក្នុងក្បាលរបស់ខ្ញុំសែនឈឺដូចគេវាយមួយដំបងអ៊ីចឹង។

«ខ្ញុំនៅទីណា?»

«យី! ម៉ាលីន! ម៉េចទៅចឹងហើយ? ឯងនៅOfficeណាំ!! ថ្ងៃហើយ! កូនណឹងមើលទៅ ថ្ងៃជាន់ហើយ! ហើយឯងយល់សប្ដិឃើញអីបានស្រែករកម៉ាក់ៗ ពេញតែការិយាល័យណឹង។ ឡើងផ្អើល អ្នកធ្វើការ ឯងឯណេះភ័យសឹងអី ក្រោកឡើង។»

ឮតែសំឡេងទេ ឯភ្នែកខ្ញុំបានបិទទៅវិញមួយសន្ទុះវិញ រួចក៏សម្រេចចិត្តបើកជាថ្មី។

«គ្នា! គ្នា! អត់អីទេណាំ!!!»

អ្នកធ្វើការរួមគ្នាទាំងអស់ទំនងជាបារម្ភពីខ្ញុំណាស់ ឃើញអើតតាមបង្អួចព្រោងព្រាត ព្រោះខ្ញុំមិនដែលអ៊ីចឹងឡើយ។ នីដាក៏លើកខ្ញុំអង្គុយឡើង! រួចបានយកទឹកក្ដៅអ៊ុនៗ ឲ្យខ្ញុំញ៉ាំ។

សំឡេងភ្លេង បានបន្លឺឡើងយ៉ាងរងំ។ ពេលនេះ ខ្ញុំនិងនីដា កំពុងជិះរថយន្តទៅភោជនីយដ្ឋាន លោកដារូ បងនីដា។ រថយន្តនីដា ត្រជាក់គ្រាន់បើ។ នីដាជាអ្នកបើកវា។

«យ៉ាងម៉េចហើយ ម៉ាលីន! ឯងអត់អីទេឬ? ហើយម៉េចមុនណឹង? ឆ្ងល់ដល់ហើយ ចេះតែថា អត់អីៗ។»

នីដាដូចជាបារម្ភពីខ្ញុំណាស់ នាងជាមិត្តជិតស្និទ្ធខ្ញុំកាលនៅរៀនមហាវិទ្យាល័យជុំគ្នា។ កាលនៅរៀន ពួកយើងឧស្សាហ៍ដើរនឹងគ្នាណាស់។

«ហ្អឺយ! តាមពិតទៅ គ្នាយល់សប្តិឃើញម៉ាក់គ្នាណា៎! គ្នាមិនដែលឃើញគាត់សោះ ឃើញតែ តាមរូបថតបន្តិចប៉ុណ្ណោះក៏បាត់រូបនោះមិនដឹងទៅណា៎សោះ។»

«អូ! ចឹងទេហ៎? កុំគិតច្រើនអី គាត់នៅបានសុកតិភពហើយ។ :) គាត់នឹងចាប់ជាតិថ្មីណា៎ សម្លាញ់កុំបារម្ភអី។»

«នីដា!!!! ប្រយ័ត្ន!!»

រថយន្តនីដាចាប់ហ្វ្រាំងទាន់ កុំអីប្រហែលជានឹងធ្វើឲ្យស្ត្រីចំណាស់ម្នាក់របួសមិនខាន។ ពួកយើង ក៏ចុះទៅ ស្របគ្នាទៅមើលគាត់។ មនុស្សម្នាខំឈប់ចោមរោមមើល។ ស្ត្រីចំណាស់នោះ គឺអ្នកមីងអម សោះ។

«អ្នកមីងអម!!» នីដានិងខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង។

«...ទើបមកដល់ផ្លូវនេះ ខ្ញុំក៏ជួបនឹងក្មួយទាំងពីរទៅណា៎!!!» មីងអមពណ៌នាពីមូលហេតុ។ ខណៈនេះ អ្នកមីងអមបានជិះរថយន្តជាមួយពួកខ្ញុំទាំងពីរ ដោយសារតែបញ្ហាមួយទើបធ្វើឲ្យគាត់រត់មក ដល់ទីនេះ។

«មីងតើផ្លូវណឹងមែន?» ខ្ញុំសួរមីងបញ្ជាក់។ «បង! ពួកខ្ញុំប្រហែលជាទៅយឺតតិចហើយ ប្រាប់ បុគ្គលិកកុំទាន់អាលរៀបចំអី ខ្លាចត្រជាក់មិនឆ្ងាញ់ទេ» នីដាហៅទូរស័ព្ទទៅដារូឲ្យពន្យាពេលជួប។

«អើស! ផ្លូវណឹងហើយក្មួយ ដែលគេប្រាប់មីងឲ្យមករង់ចាំ!» មីងអមប្រាប់ខ្ញុំពីផ្លូវដែលគាត់នឹង ត្រូវមកជួបនឹងកូនប្រុសគាត់។ «ចុះមីងមិនប្រាប់ថាមីងរវល់ធ្វើការទៅ» ខ្ញុំតបទៅវិញ ឯនីដាក៏ជិះទៅតាម

ពាក្យបង្គាប់របស់ខ្ញុំដែរ។«ហ្អើយ! ស្មានតែមីងមិនបានប្រាប់ឬ? មីងប្រាប់ហើយតែគេនៅតែមានះ! ធ្វើម៉េចអំ!!! ឈប់ត្រង់នេះហើយក្មួយ!!! បន្តិចទៀត គេនឹងមកជួបក្មួយ គេថាមានកិច្ចការចង់ពឹងពាក់ក្មួយ ទាល់តែជួបគ្នាផ្ទាល់ទើបហ៊ាននិយាយ! អូ! គេថាឲ្យយើងចូលទៅចាំគេនៅហាងភីហ្សានេះ!»

ថ្ងៃនេះ មីងអមដូចជាចម្លែកណាស់ ភ័យៗ! យ៉ាងម៉េចទេ តែដើម្បីចង់ដឹងរឿងពិត ខ្ញុំក៏ទៅតាមគាត់។ ចូលដល់ភីហ្សា ពួកយើងក៏អង្គុយរង់ចាំ!!! ថ្ងៃនេះ ស្ងាត់ភ្ញៀវណាស់ គឺមានតែតុពួកខ្ញុំទេ។

សម្រែកមួយបានបន្លឺឡើងៈ «ជូនពរថ្ងៃកំណើត! Happy birthday to you!!! Happy birthday to you!!!» នំខេកដ៏ធំមួយ ត្រូវបានបុគ្គលិកភីហ្សាប៉ុន្មាននាក់កាន់យកមក។ ខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង រួចក៏នឹកឆ្ងល់ ព្រោះគ្មានអ្នកណាដឹងពីថ្ងៃកំណើតរបស់ខ្ញុំទេ គឺសូម្បីតែខ្ញុំ និងប៉ាខ្ញុំ។ បាំងបុគ្គលិកភីហ្សាបន្តិច ស្រាប់តែលោកប៉ាខ្ញុំ និងមនុស្សប្រុសពីរបីនាក់ សុទ្ធតែពាក់អាវស ខោរខ្មៅ មានកាដូម្នាក់មួយទាំងអស់។

«ជូនពរថ្ងៃកំណើតកូនសម្លាញ់!!!» ប៉ានិយាយមកកាន់ខ្ញុំ។ ខ្ញុំដូចជាមិនយល់សោះ ហើយក៏កាន់តែមិនយល់ទៅទៀតថាមានរឿងហេតុអី ឬក៏ពួកគេលេងសើចនឹងខ្ញុំនោះទេ?

«ជូនពរថ្ងៃកំណើតណាស្រីពៅ!!» បុរសម្នាក់បានពោលបែបនេះ មកកាន់ខ្ញុំដែរ ដោយក្នុងដៃរបស់គេមានកាដូដ៏ធំមួយដែរ។ ខ្ញុំមិនដឹងត្រូវនិយាយយ៉ាងម៉េចទេ។

«នេះជាកាដូរបស់ម៉ាក់ណាំ!!!» អ្នកមីងអមដែលអង្គុយក្បែរខ្ញុំនេះ ក៏ពោលបែបនេះដែរ។ ខ្ញុំយកដៃក្តិចថ្ពាល់ខ្ញុំ រួចគិតថានេះ ជាយល់សប្តិទេឬ?

«ម៉េចហើយ កូនស្រីសំណព្វចិត្តប៉ា! ឯងក្តិចថ្ពាល់នេះ ខ្លាចមិនមែនជាការពិតឬ? តស់! ប៉ងប្រាថ្នា និងពន្លត់ទៀនសិនចាំប៉ានិយាយរឿងឲ្យស្តាប់ណាំ!»

ប៉ងអីទៅ! គិតអីទៅ! ខ្ញុំសែនឆ្ងល់ណាស់នៀក តែជាសំណូមពរខ្ញុំក៏ធ្វើតាមពួកគាត់។ នីដាមើលមុខខ្ញុំ ទាំងងឿងឆ្ងល់ដូចគ្នា។ ពន្លត់ទៀនចប់ ប៉ាក៏មានប្រសាសន៍ឡើងថាៈ

«កូនពិតជាភ្ញាក់ផ្អើលហើយ ដែលប៉ាមិនបានប្រាប់មុនបែបនេះ។ តាមពិត ប៉ានិងម៉ាក់ឯង ដឹងគ្នាជិតបីបួនឆ្នាំមកហើយ។ ការងារទូទៅ នៅក្នុងក្រុមហ៊ុននោះ គឺប៉ាបានប្រគល់ឲ្យម៉ាក់ឯងគ្រប់គ្រង។ ម៉ាក់ឯងនិងប៉ា បានវង្វេងគ្នាយូរមកហើយ ដោយគេបានទៅរស់នៅសហរដ្ឋ រកស៊ីរហូតមានមុខជំនួញមួយ ក៏

ចាប់ផ្តើមវិលត្រឡប់មករកប៉ានេះ កាលពីឆ្នាំ២០០៤ រហូតដល់ឆ្នាំ២០០៦ ឬ២០០៧នោះ ទើបពួកយើងរកគ្នាឃើញ តែម៉ាក់ឯងបានប្រាប់ប៉ាថា មិនត្រូវប្រាប់ឯងឲ្យដឹងនោះទេ។ ម៉ាក់ឯងចង់ឲ្យឯងរៀនលត់ដំខ្លួនឯងឲ្យបានច្រើន ទើបបានជាប៉ាតែងតែកុហកឯងបែបនេះ។ ហិហិហ! ពេលរាល់ដងដែលប៉ានិយាយពីម៉ាក់ឯងហើយយំនោះ មិនមែនប៉ានឹកម៉ាក់ឯងនោះទេ គឺប៉ានិយាយកុហកឯងថាម៉ាក់ឯងស្លាប់ប៉ុណ្ណោះ។ នេះគឺបងប្រុសឯងដែលទៅនៅជាមួយម៉ាក់ឯងណា៎!!! ប៉ាលាក់រឿងនេះយូរហើយ តែព្រឹកមិញនេះ បងប្រុសឯងចេះតែអន្ទះអន្ទែងចង់ជាប់មុខឯង ព្រោះគេថាគេបានជួបឯងលើដងផ្លូវក្បែរផ្សារថ្មីគឺស្អាតណាស់ឥឡូវនេះ។ រួចបងប្រុសឯងមួយទៀត គេក៏សាកលេងហ្វេសប៊ុគជាមួយឯង និងចង់ជូនពរឯងទៀតតែចេះប៉ា នៅជិតនោះឃាត់ទាន់ កុំអីបែកការបាត់។ អស់សំណើចមែនគ្រួសារយើងហ្ន៎!! តែបានជួបជុំវិញអីចឹងសប្បាយណាស់។»

«ប៉ា!! តែកូនដូចជាមិនទាន់យល់សោះ ហេតុអីម៉ាក់ត្រូវធ្វើចឹងជាមួយកូន? កូនមិនសប្បាយចិត្តទេ?»

ពួកគេស្រាប់តែធ្លាក់ទឹកមុខទាំងអស់។ ខ្ញុំដឹងថាវាសំណួរហ្មងសៅមួយ តែខ្ញុំនៅតែឆ្ងល់ ព្រោះគាត់មិនបានធ្វើឲ្យខ្ញុំបានសុខទុក្ខនឹងភាពកក់ក្តៅពីម្តាយ។ ខ្ញុំបានរស់នៅកំព្រាស្ទើរតែពាក់កណ្តាលជីវិតទៅហើយ។ ខ្ញុំត្រូវគេមើលងាយ មើលបំណាំថា ជាកូនកំព្រាម្តាយ ខ្ញុំឈឺចាប់ណាស់។ រាល់ពេល ខ្ញុំពុំដែលមានបងប្អូនឯណាដូចគេ ត្រូវចែករំលែកនោះទេ គឺមានតែមិត្តភក្តិ ពេលខ្លះ គេក៏សប្បាយចិត្តជួយទៅ ពេលខ្លះគេក៏ជួយទាំងមិនសប្បាយចិត្តទៅ តើនេះឬជាការលត់ដំដែលពួកគាត់ផ្តល់ឲ្យខ្ញុំ?

ខ្ញុំមិននិយាយអ្វីនោះទេ ខ្ញុំគ្រាន់តែដឹងថាខ្ញុំចង់នៅស្ងប់ស្ងាត់ម្នាក់ឯង។ ខ្ញុំបានបង្គាប់នីដា ឲ្យទៅអង្គុយនៅហាងបងប្រុសនាង ក្នុងបន្ទប់មួយស្ងប់ស្ងាត់។ ក្នុងបន្ទប់ ទឹកភ្នែកខ្ញុំហូរឥតឈប់នោះទេ។ ទឹកភ្នែកខ្ញុំក្តៅណាស់ នេះបញ្ជាក់ពីអារម្មណ៍ច្របូកច្របល់ ស្មានមិនត្រូវនៃជីវិតនៅត្រង់ណេះ។ នីដា នៅក្បែរខ្ញុំទះខ្នងខ្ញុំជានិច្ច។ មួយសន្ទុះក្រោយមក សំឡេងគោះទ្វាមួយក៏បង្លើបឡើងតិចៗ ជាមួយនឹងសំឡេងមនុស្សប្រុសចំណាស់ម្នាក់៖

«កូន! ប៉ាណា៎! ឲ្យប៉ាសូមទោសផង! ម៉ាក់ឯងនៅចាំក្រៅ!»

«ខ្ញុំមិនចង់ជួបអ្នកណាទាំងអស់» ខ្ញុំស្រែកគំហក់ទៅវិញទាំងទឹកភ្នែករហាម។

«បាន! បាន!! ប៉ានៅចាំក្រៅ! នីដា! ឯងជួយមើលគេជំនួសពូផងណា៎!» ប៉ាផ្ដាំនីដា! នីដាគ្នាមិនដឹងអីទេ គ្នានៅតែទះស្មាខ្ញុំ។

«ចាំ! លោកអ៊ុំ! ចាំខ្ញុំមើលនាងឲ្យ...» ស្ងប់បន្តិច នីដាក៏និយាយមកកាន់ខ្ញុំ។

«ម៉ាលីន! ឯងដឹងទេ មនុស្សមិនមែនរស់មួយថ្ងៃនោះទេ គឺមនុស្សរស់មួយជីវិតណា៎! ក្រែងឯងធ្លាប់ប្រាប់ខ្ញុំ និងឧស្សាហ៍សួរខ្លួនឯងណាស់មែនទេ ថាឯងចង់ដឹងថាឯងជានរណា? ឯងចង់បានអ្វី? ពេលនេះ ឯងដឹងហើយតើ គឺឯងជានីដា កូនលោកអ៊ុំប្រុស និងលោកអ៊ុំស្រីទាំងពីរ ដែលមានបងប្អូន៣នាក់។ មនុស្សដែលឯងចង់ជួប តែមិនដឹងថាចង់ជួបនោះ គាត់បានមកដល់ហើយតើ គឺអ្នកម៉ាក់របស់ឯង ដ្បិតបើឯងមិនដែលបានកក់ក្ដៅនឹងជីវិតពេញលេញជាមួយគ្រួសារក៏ពិតមែន តែឯងបានស្គាល់ខ្លួនឯង ឯងមានអ្វីគ្រប់គ្រាន់មកវិញហើយ។ ឯងត្រូវរក្សាវាឲ្យបានល្អណា៎! ពេលវេលាមិនចាំយើងទេ កាន់តែមិនទទួលស្គាល់ ពេលវេលាក៏កាន់តែដើរទៅមុខដោយឥតបានការដែរ...។»

និយាយដល់ត្រឹមនេះ ខ្ញុំស្រាប់តែនឹកឃើញយល់សប្ដិដ៏ខ្លីពីព្រឹកមិញរបស់លោកយាយអាថ៌កំបាំងចំណាស់ម្នាក់៖ «... សូម្បីតែឯងថយទៅក្រោយមួយជំហាន ក៏មានន័យថាឯងដើរទៅមុខមួយជំហៀនដែរ...»។ ហេតុអី ខ្ញុំបែរជាខ្លាចនឹងការពិតនេះទៅវិញ?

«ម៉ាលីន! ឯងគឺនៅតែជាឯង ម៉ាលីនដែលជាមិត្តល្អរបស់ខ្ញុំណា៎!! ជូតទឹកភ្នែកចេញទៅ ម៉ោះ!»

នីដាជូតទឹកភ្នែកខ្ញុំ និងធ្វើឲ្យខ្ញុំរំភើបរហូតដល់ងក់ក្បាលដោយមិនដឹងខ្លួន។ ខ្ញុំបានដើរចេញទៅជួបម៉ាក់និងប៉ារបស់ខ្ញុំ ដោយឃើញទឹកភ្នែករបស់ម៉ាក់ខ្ញុំហូររហាមផងដែរ។ ខ្ញុំរត់ទៅឱបពួកគាត់យ៉ាងកក់ក្ដៅបំផុតក្នុងជីវិតខ្ញុំ។ នេះជាលើកទី១ ហើយដែលខ្ញុំស្គាល់ថាខ្ញុំគឺជាខ្ញុំ ខ្ញុំគឺជាកូនរបស់ម៉ាក់និងប៉ា មនុស្សដែលមានសំណាងជាងគេក្នុងលោក។

«កូនស្រលាញ់ម៉ាក់និងប៉ា កូនស្រឡាញ់បងៗ!!!»

អំណែះតទៅ ចម្ងល់ដែលឆ្ងល់ទាំងប៉ុន្មានក្នុងជីវិតរបស់ខ្ញុំក៏បានរសាត់ក្លាយជាសុបិនមួយ ដែលមានត្រឹមតែអក្សរជាប់នឹងសៀវភៅកំណត់ហេតុជីវិតរបស់ខ្ញុំ ក្រោមដួងច័ន្ទនៃរាត្រីថ្មីប៉ុណ្ណោះ ឯការពិតបានរសាត់តាមរាត្រីរនោចអស់ហើយ។ សូមឲ្យមនុស្សគ្រប់រូបចេះ ប្រឈមមុខនឹងការពិតដែលខ្លួនមាន។ រក្សាទុកនូវអ្វីដែលខ្លួនមាន និងមិនត្រូវសោកស្ដាយពីអ្វីដែលខ្លួនបាត់បង់នោះទេ គឺត្រូវតែ

ជោគជ័យ!!!

និពន្ធដោយ ម៉ា ច័ន្ទបញ្ញា (ស្នាមញញឹម)

ភ្នំពេញ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១